គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)
Committee For Free And Fair Elections In Cambodia (COMFREL)
ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

ខុមហ្វ្រែល COMFREL

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារ៉ា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឹន សែត**
**Mr. SEN Set**

ស.ប្រ.ក.៣/លេខ ១៦/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុង ខេត្ត កំពង់ចាម

*ភ្នំពេញ, ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៩២នាក់ មកពីស្រុកនានា នៅក្នុងខេត្តកំពង់ចាម និងមានសិក្ខាកាមស្ត្រីចូលរួមប្រមាណ ៥២% បានជួបជុំគ្នានៅក្នុងសិក្ខាសាលា ម្ចាស់ឆ្នោតក្នុងការកំណត់ លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តកំពង់ចាម ។

អភិបាលរងខេត្តកំពង់ចាម លោកស្រី **ខុង ស៊ុនអេង** បានលើកឡើងថា កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ របស់រាជរដ្ឋាភិបាល គ្របដណ្តប់ស្ទើរគ្រប់វិស័យ ។

អ្នកតំណាងរាស្ត្រ **ថាក់ ឡានី** មណ្ឌលកំពង់ចាមក៏បានលើកឡើងថា សិក្ខាសាលានេះជាឱកាសមួយដើម្បីប្រគល់សិទ្ធិអោយម្ចាស់ឆ្នោតបញ្ចេញនូវអ្វីដែលគាត់ចង់បាន។ លោកជំទាវ ថាក់ ឡានី បានសន្យាថា *"ក្នុងនាមខ្ញុំជាតំណាងរាស្ត្រខ្ញុំនឹងយករាល់ការសំណូមពររបស់អស់លោកដើម្បីដាក់ជូនទៅថ្នាក់លើ,,,ហើយយើងរួមគ្នាកសាងប្រទេសជាតិ ។"*

ជាលទ្ធផលម្ចាស់ឆ្នោតបានពិភាក្សាកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង ១០ ក្នុងខេត្តកំពង់ចាមដូចខាងក្រោមៈ

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តកំពង់ចាមរួមមានៈ

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពទាំងដប់នៅក្នុងខេត្ត កំពង់ចាម** |
|---|
| ១) សុំឱ្យរកទីផ្សារសំរាប់លក់កសិផល ដោយកំណត់តម្លៃ ដូចជា ស្រូវ ឱ្យបានស្មើនឹង ៣០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ, សណ្តែកសៀង ឱ្យបានស្មើនឹង ៥០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ,ដំឡូងមីក្រៀម ឱ្យបានស្មើនឹង ២០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ និង ល្ង ឱ្យបានស្មើនឹង ១០០% ក្នុងតម្លៃប្រេងសាំង ០១លីត្រ [អោយបាននៅចុងឆ្នាំ ២០០៩] ។ |

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាសលាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់ ។

| |
|---|
| ២) សុំជំរុញឱ្យមានការអនុម័តលក្ខន្តិកក្រមសីលធម៌ សំរាប់ចៅក្រម និង ព្រះរាជអាជ្ញា ឱ្យបានមុនឆ្នាំ២០១០ ។ |
| ៣) សុំកុំឱ្យយកប្រាក់ពីអ្នកជំងឺ ដែលមកព្យាបាលនៅមន្ទីរពេទ្យរដ្ឋ ចាប់ពីខែ១០ ឆ្នាំ២០០៩ នេះតទៅ និងសុំឱ្យបុគ្គលិកសុខាភិបាល គោរពក្រមសីលធម៌ និងវិជ្ជាជីវៈរបស់ខ្លួនឱ្យបានចាប់ពីដើមឆ្នាំ២០១០ នេះតទៅ។ |
| ៤) សំណូមពរដល់តំណាងរាស្ត្រ រដ្ឋាភិបាល ជំរុញឱ្យអាជ្ញាធរ ភូមិ ឃុំ ស្រុក ខេត្ត និងស្ថាប័នពាក់ព័ន្ធ ឈប់យកប្រាក់ពីថ្លៃសេវាកម្ម ដូចជា សំបុត្រអាពាហ៍ពិពាហ៍ ធ្វើអត្តសញ្ញាណប័ណ្ណ ... និងឱ្យមាន ប្រសិទ្ធិភាព គោរពក្រមសីលធម៌ ចាប់ពីចុងឆ្នាំ ២០០៩ នេះតទៅ។ |
| ៥) សុំផ្ទេរ ឬប្រគល់ការគ្រប់គ្រងរមណីយដ្ឋានទឹកឆា ដែលសព្វថ្ងៃគ្រប់គ្រងដោយឯកជន មកនៅក្រោមការគ្រប់គ្រងរបស់សហគមន៍[២] ចាប់ពីដើមឆ្នាំ២០១០ តទៅ។ |
| ៦) សុំឱ្យសមត្ថកិច្ចបញ្ឈប់ការយកប្រាក់ពីជនរងគ្រោះ នៅពេលជនរងគ្រោះទៅយកវត្ថុតាង ដូចជា ម៉ូតូ គោ ក្របី ... ដែលសមត្ថកិច្ចដកហូតបានពីចោរ ចាប់ពីខែ ១០ ឆ្នាំ២០០៩ នេះតទៅ។ |
| ៧) សំណូមពរឱ្យរាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ធ្វើយុទ្ធនាការថ្នាក់ជាតិ (ដូចជាការដង្ហែរជាក្បួន ឬប្រារព្ធពិធីផ្សេងៗ,.,.,.,.) សំរាប់ប្រឆាំងទៅនឹងនិទណ្ឌភាព នៅទូទាំងខេត្តកំពង់ចាម ចាបផ្តើមពីឆ្នាំ២០១០ នេះតទៅ។ |
| ៨) សុំបំបាត់ការប្រមូលលុយពីសិស្ស (ក្នុងម៉ោងសិក្សា, ពេលប្រលង និងទិញពិន្ទុពីគ្រូ) នៅទូទាំង ខេត្តកំពង់ចាម ចាប់ផ្តើមនៅដើមឆ្នាំ២០១០ នេះតទៅ ។ |
| ៩) សុំផ្លូវចាក់គ្រួសក្រហម ប្រវែង ៧គីឡូម៉ែត្រ ទទឹង ៥ម ដាក់លូមួយកន្លែង ចាប់ពីភូមិផ្ទះខ្ពស់ ដល់បឹង អូរតាញៀន ឃុំតុងរ៉ុង ស្រុកព្រៃឈរ កសាងចាប់ពីឆ្នាំ២០១០ ដល់២០១២។ និងមួយខ្សែទៀតប្រវែង ៦គីឡូម៉ែត្រ ទទឹង ៦ម ចាប់ពីភូមិ មៀន ត្រង់ក្លោងទ្វារ ឃ្លោយ ដល់បឹងធំ ចាប់កសាងពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០។សុំកសាងផ្លូវគ្រួសក្រហមឡើងវិញ មួយខ្សែ ពីទំនប់កែងថ្មដារ ទល់ផ្លូវស្វាយភ្លើង ភូមិស្វាយភ្លើង ឃុំស្វាយភ្លើង ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានប្រវែង ៥គីឡូម៉ែត្រ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២។ |
| ១០) សុំឱ្យមានដីសម្បទានសង្គមកិច្ច ដើម្បីចែកឱ្យប្រជាពលរដ្ឋក្រីក្រ សំរាប់ធ្វើកសិកម្មគ្រួសារដោយក្នុង មួយគ្រួសារយ៉ាងតិចអោយបានពីរហិចតា ចាប់ពីដើមឆ្នាំ២០១០ ឱ្យចប់ក្នុង ឆ្នាំ២០១២ និង សុំការបណ្តុះបណ្តាលបច្ចេកទេសកសិកម្មតម្រូវតាមពូជជាក់ស្តែង អោយបានពីរវគ្គ ក្នុងមួយឃុំ សំរាប់ រយៈពេល ១ ឆមាស អោយបាននៅទូទាំងខេត្តកំពង់ចាម ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកព្រៃឈរ ស្រុកក្រូចឆ្មារ ស្រុកត្បូងឃ្មុំ និងក្រុងកំពង់ចាម នៅក្នុងខេត្តកំពង់ចាម ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោតនៅតាមមណ្ឌលនីមួយៗ:

[២] ដូចជា សហគមន៍ស្រីគ្រប់លក្ខណ៍។

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨
២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន
៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នក-តំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*

- លោក **ចំន ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦